Declassified to Public
12 June 2020



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Feb-2017, 12:40
CMS/CFO: Ly Bunloung

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បញ្ចូលឯកសារនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង០០២ (D193/97)

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ ម៉ូស្សេនី
Suzana TOMANOVIĆ

**មេធាវីតំណាង**

**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ីន សូវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Beini Ye

## I- ប្រវត្តិនីតិវិធី និងសារណា

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ ត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

2. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ លោកចៅក្រម Mark Harmon បានចេញ*ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២*[1]។ ខ្ញុំសូមដាក់បញ្ចូលកថាខណ្ឌ ១ ដល់៧ នៃដីកាសម្រេចនោះ ដោយធ្វើការលើកយោងទៅកថាខណ្ឌទាំងនេះ។

3. នៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ខ្ញុំបានចេញ*អនុស្សរណៈពីសហចៅក្រមអន្តរជាតិជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹង "ការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២"*។ ក្នុងអនុស្សរណៈនោះ ខ្ញុំបានកំណត់លក្ខខណ្ឌ និងទម្រង់មួយចំនួនសម្រាប់ការដាក់បង្ហាញឯកសារ[2]។

4. នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ការស្នើសុំការអនុញ្ញាតការដាក់បង្ហាញឯកសារចំនួន ១០ ពីសំណុំរឿង ០០៤ ទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២[3]។

5. យោងលើភាពបន្ទាន់ដោយសារតែសក្ខីកម្មរបស់សាក្សីទាំងនេះដែលត្រូវបានកំណត់ពេលរួចហើយនោះ ស.ព.អ បានផ្តល់ឯកសារចម្លងនៃសំណើនេះដល់ក្រុមមេធាវីការពារក្តី និងស្នើឲ្យក្រុមមេធាវីការពារក្តី ធ្វើការឆ្លើយតបតាមរយៈអ៊ីម៉ែល។ ក្រុមមេធាវីការពារក្តី អោ អាន បានឆ្លើយតបតាមអ៊ី

---

[1] សំណុំរឿងលេខ 004-D193/4, *ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២* ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

[2] សំណុំរឿងលេខ 004-D273, *អនុស្សរណៈពីសហចៅក្រមអន្តរជាតិជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹង "ការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២"* ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[3] សំណុំរឿងលេខ 004-D193/97, *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២* ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ។

ម៉ែល នៅថ្ងៃទី ១៣ ខែ កញ្ញា ហើយក្រុមមេធាវីការពារក្តី យឹម ទិត្យ ឆ្លើយតបនៅថ្ងៃទី ១៤ ខែ កញ្ញា ដោយលើកឡើងថា ពួកគាត់ពុំមានបំណងធ្វើការឆ្លើយតបឡើយ។ អ៊ីម៉ែលពីក្រុមមេធាវីការពារក្តីត្រូវបានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ ក។

## II- ពិភាក្សា

6. ឯកសារដែលបានស្នើឡើងចំនួន ១០ រួមមាន កំណត់ហេតុស្តាប់ចម្លើយចំនួន ២, របាយការណ៍ស្តីពីការអនុវត្តកិច្ចស៊ើបសួរចំនួន ៣ និងឯកសារចំនួន ៥ ដែលជាឯកសារភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បង្ហាញនាពេលកន្លងមក[4]។ ឯកសារដែលបានស្នើឡើងទាំងអស់ លើកលែងតែឯកសារ ១ សុទ្ធតែជាប់ទាក់ទង *ជាបឋម* ទៅនឹងសំណុំរឿង០០២ ដោយសារឯកសារទាំងនេះជាប់ទាក់ទងនឹងសាក្សីដែលត្រូវបានកំណត់ពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយការដាក់បង្ហាញឯកសារទាំងនេះនឹងមិនប៉ះពាល់ទៅដល់សុចរិតភាព និងភាពសម្ងាត់នៃកិច្ចស៊ើបសួរឡើយ។ ត្រង់ចំណុចដែលថាភស្តុតាងរបស់ពួកគេទាក់ទងនឹងកិច្ចស៊ើបសួរដែលកំពុងបន្តធ្វើនៅក្នុងសំណុំរឿង០០៤ នេះ សាក្សីចំនួន ៤ រូប អាចត្រូវបានចាត់ថ្នាក់ជាសាក្សីប្រភេទ ក។

7. ឯកសារមួយ គឺ ឯកសារ D219/786 ដែលខ្ញុំយល់ឃើញថាពុំមានភាពជាប់ទាក់ទង*ជាបឋម* មិនមានចម្លើយរបស់សាក្សីដែល ស.ព.អ បញ្ជាក់ថាមានឡើយ។ ទោះបីជាមានឈ្មោះរបស់សាក្សីនៅក្នុងឯកសារនោះក៏ដោយ ក៏ឈ្មោះរបស់គាត់ត្រូវបានលើកឡើងទាក់ទងទៅនឹងកន្លែងរស់នៅរបស់បុគ្គលម្នាក់ទៀតប៉ុណ្ណោះ។ ដូច្នេះ ការដាក់បង្ហាញរបាយការណ៍ស្តីពីការអនុវត្តកិច្ចស៊ើបសួរនោះ នឹងត្រូវបានបដិសេធ។

8. លើសពីនេះទៀត របាយការណ៍ស្តីពីការអនុវត្តកិច្ចស៊ើបសួរចំនួន ២ ទៀត គឺ ឯកសារ D118/70 និង D118/74 នឹងត្រូវអនុញ្ញាតឲ្យដាក់បង្ហាញ ដោយមានការកោសលុប ដោយផ្តល់តែឯកសារដែលបានស្នើឡើងយ៉ាងជាក់លាក់ទាក់ទងនឹងសាក្សីដែលជាប់ទាក់ទងតែប៉ុណ្ណោះ។

9. ជាចុងក្រោយ ខ្ញុំកត់សម្គាល់ថា ឯកសារចំនួន ៥ ដែលភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយ D210/671 ដែលបានដាក់បង្ហាញនាពេលកន្លងមក គួរតែត្រូវបានស្នើសុំឲ្យដាក់បង្ហាញដោយយកចិត្តទុកដាក់ ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយដើម។ ការធ្វើបែបនេះគឺដើម្បីធ្វើឲ្យមានការប្រើប្រាស់ធនធានរបស់ការិយាល័យរបស់ខ្ញុំកាន់តែមានភាពប្រសើរ និងប្រកបដោយប្រសិទ្ធភាព នៅ

---

[4] សំណើ, ឧបសម្ព័ន្ធ ក

ពេលជួយសម្រួលដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២ តាមរយៈការអនុញ្ញាតឲ្យដាក់បង្ហាញឯកសារឲ្យបានទាន់ពេលវេលា និងជាប្រចាំ។

10. ដើម្បីឲ្យស្របទៅតាមការពិនិត្យមើលដែលកំពុងធ្វើទៅលើភាពចាំបាច់នៃការអនុវត្តប្រភេទ គ ចំពោះសាក្សី ខ្ញុំយល់ឃើញថា សាក្សីចំនួន ៣ រូប ដែលបានដាក់បង្ហាញនាពេលកន្លងមក ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានមូលដ្ឋានអ្វីត្រូវធ្វើចំណាត់ថ្នាក់តឹងរឹងជាងនេះនៅទេ។ ដូច្នេះ ខ្ញុំនឹងកែប្រែចំណាត់ប្រភេទ ប្រាក់ យុត, យ៉ូ វ៉ាន់ និង ណុប ងឹម ជាប្រភេទ ក វិញ។ ទោះបីជារក្សាការសម្ងាត់នៃឯកសារដែលបានដាក់បង្ហាញ ដើម្បីធានាសុចរិតភាពនៃកិច្ចស៊ើបសួរ ខ្ញុំលែងតម្រូវឲ្យរក្សាការសម្ងាត់ចំពោះអត្តសញ្ញាណរបស់ពួកគេទៀតហើយ។

11. ដីកាសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ដោយការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយ ដោយសារភាពបន្ទាន់នៃបញ្ហានេះ និងដោយសារតែធនធានផ្នែកបកប្រែភាសាមានកម្រិត។

**តាមសំអាងហេតុខាងលើ យើង៖**

**12.** **អនុញ្ញាត**ឲ្យដាក់បង្ហាញឯកសារចំនួន៩ នៅក្នុង**ឧបសម្ព័ន្ធ ខ** ជូនអង្គជំនុំជម្រះសាលាដំបូង និង ភាគីក្នុងសំណុំរឿង០០២។ យោងទៅលើការសម្ងាត់ និងភាពរសើបនៃកិច្ចស៊ើបសួរដែលកំពុងអនុវត្តក្នុងសំណុំរឿង០០៤ ឯកសារទាំងនេះត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ដូចលើកឡើងនៅក្នុង **ឧបសម្ព័ន្ធ ខ** ក្នុងទម្រង់ និងលក្ខខណ្ឌខាងក្រោម៖

(ក) ឯកសារទាំងអស់ដែលបានផ្តល់ពីសំណុំរឿង ០០៤ ត្រូវចាត់ជាឯកសារសម្ងាត់។

(ខ) ក្នុងករណីដែលឯកសារដែលផ្តល់ឲ្យ ដោយអនុលោមតាមដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២ ឯកសារនោះនឹងត្រូវចាត់ជាឯកសារសម្ងាត់។

(គ) ក្នុងករណីសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលឯកសាររបស់ខ្លួន ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ត្រូវបានកោះឲ្យមកផ្តល់សក្ខីកម្ម ពួកគាត់អាចផ្តល់សក្ខីកម្មក្នុងសវនាការជាសាធារណៈ ប៉ុន្តែឈ្មោះ និងអត្តសញ្ញាណរបស់ពួកគាត់ ត្រូវបានរក្សាការសម្ងាត់។

(ឃ) មិនត្រូវផ្សព្វផ្សាយឯកសារដែលផ្តល់ឲ្យ យោងតាមដីកាសម្រេចនេះ ដល់បុគ្គលណាឡើយ ក្រៅពីបុគ្គលដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចនេះ។

(ង) មិនត្រូវផ្សព្វផ្សាយឯកសារដែលបានផ្តល់ឲ្យ យោងតាមដីកាសម្រេចនេះ ទៅដល់សាធារណជន លើសពីភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការសាធារណៈ ក្នុងទម្រង់ណាមួយ ឬតាមប្រព័ន្ធផ្សព្វផ្សាយក្នុងទម្រង់ណាមួយឡើយ។

(ច) ភាគី ឬ ក្រុមមេធាវីការពារក្តីណាមួយ ឬបុគ្គលផ្សេងណាមួយ ដែលអាន ដកស្រង់ ឬប្រើប្រាស់ឯកសារណាមួយដែលត្រូវបានដាក់បង្ហាញ ត្រូវកំណត់អត្តសញ្ញាណរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈរហស្សនាមរបស់ពួកគេក្នុងសំណុំរឿង ០០២ តែប៉ុណ្ណោះ និងប្រើប្រាស់សេចក្តីពិពណ៌នាដោយពិចារណាឲ្យបានសមស្រប ដើម្បីជៀសវាងការកំណត់អត្តសញ្ញាណរបស់សាក្សី តាមរយៈព័ត៌មានផ្សេងទៀត។

(ឆ) ឯកសារដែលបានដាក់បង្ហាញ ត្រូវផ្តល់ជូនក្រុមមេធាវីការពារក្តីនៃជនជាប់ចោទទាំងពីរ មេធាវីប្រចាំការការពារក្តី ខៀវ សំផន ("មេធាវីប្រចាំការ") និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈឯកសារចម្លងអេឡិចត្រូនិក។

(ជ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញឯកសារដែលបានផ្តល់ឲ្យ ដោយអនុលោមតាមដីកាសម្រេចនេះ ទៅដល់តែសមាជិកនៃក្រុមរបស់ខ្លួនដែលបានកំណត់ជាផ្លូវការ យោងតាមវិធាន ២២ (៥) និងវិធាន ១២ ស្ទួនពីរ (៤) និងកម្មសិក្សាការីដែលត្រូវបានតែងតាំងជាផ្លូវការប៉ុណ្ណោះ។

(ឈ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងឯកសារដើមដែលបានផ្តល់ឲ្យខ្លួន ក្រៅពីការប្រើប្រាស់ផ្ទៃក្នុងដោយសមាជិកក្រុមរបស់ខ្លួន ដែលទទួលបានការណែនាំ ឬត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារសម្ងាត់ឡើយ។

(ញ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ត្រាដែលអាចពិនិត្យឡើងវិញ នៃឯកសារដែលពួកគេបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និង

(ដ) ប្រសិនបើសមាជិកណាមួយនៃភាគី ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២ ដឹងអំពីឯកសារចម្លងដែលមិនត្រូវបានអនុញ្ញាត ដែលត្រូវបានដាក់បង្ហាញ គាត់ត្រូវចាត់វិធានការទាំងឡាយជាបន្ទាន់ ដើម្បីរក្សាឯកសារចម្លងនោះឲ្យមានសុវត្ថិភាព និងប្រគល់វាទៅឲ្យសហចៅក្រមស៊ើបអង្កេត និង

(ថ) ប្រសិនបើសមាជិកណាមួយនៃភាគី ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២ ដឹងអំពីការបំពានលើលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ គាត់ត្រូវរាយការណ៍ជាបន្ទាន់ទៅដល់សហចៅក្រមស៊ើបអង្កេត។

13. **បដិសេធ**សំណើទាក់ទងនឹងរបាយការណ៍ស្ដីពីការអនុវត្តកិច្ចស៊ើបសួរ D219/786។

14. **បញ្ជាក់**ថា គោលបំណងនៃដីកាសម្រេចនេះ “សាធារណៈ” មានន័យថា និងរួមបញ្ចូលបុគ្គលទាំងអស់ រដ្ឋាភិបាល អង្គការ ស្ថាប័ន កូនក្ដី សមាគម និងក្រុមនានា ក្រៅពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា និងតំណាងរបស់គាត់ ជនជាប់ចោទ បុគ្គលិកដែលបានកំណត់ដោយអនុលោមទៅតាមវិធាន២២ (៥) និង១២ ស្ទួនពីរ (៤) ដែលទទួលបានការអនុញ្ញាតពីក្រុមមេធាវីការពារក្ដី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ឱ្យចូលពិនិត្យមើលឯកសារសម្ងាត់។ “សាធារណៈ” ក៏រួមបញ្ចូល ដោយគ្មានការកំណត់ សមាជិកគ្រួសារ មិត្តភ័ក្ដិ និងមិត្តភ័ក្ដិជិតស្និទ្ធរបស់ជនជាប់ចោទ, ជនជាប់ចោទ ក្រុមមេធាវីការពារក្ដី និងសមាជិកនៃបុគ្គលិកក្នុងសំណុំរឿងផ្សេងទៀត ឬកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន។

15. **កែប្រែ**ការចាត់ប្រភេទសាក្សី ប្រាក់ យុត, យូ វ៉ាន់ និងណុប ង៉ឹម ពីប្រភេទ គ ទៅប្រភេទ ក នៅក្រោមលក្ខខណ្ឌខាងលើ លែកលែងតែកថាខណ្ឌ ១២ (គ) និង (៣២) (ង) ។

16. **បញ្ជាក់**ថា លក្ខខណ្ឌ និងការដាក់កម្រិតខាងលើ ត្រូវរក្សាដដែល រហូតដល់លក្ខខណ្ឌ និងការដាក់កម្រិតទាំងនោះ ត្រូវបានកែប្រែ តាមរយៈដីកាសម្រេចដ៏ជាក់លាក់មួយ ដោយសហចៅក្រមស៊ើបអង្កេត ឬ ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ត្រូវបានចេញ និង

17. **ស្នើឱ្យ**អង្គជំនុំជម្រះសាលាដំបូង ធានាថាភាគីទាំងអស់ អនុវត្តតាមដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d’instruction International**